Ms. SMAN Norany
sman.norany@rupp.edu.kh
Tel: 012 606 804 (Cambodia)

*TOWARD A BETTER UNDETSTANDING OF*

# WOMEN'S RIGHTS IN ISLAM

## Muslim Women's Rights To And Responsibility For Education

**Updated in 2023**
**(1445, Islamic Calendar)**

**Abstract**

Generalizations about Islam and human rights in Islam are seen replete in today's media, especially, the misconceptions on Muslim women's rights viewed by most people who shape their image through the world of media. Islam provides peaceful, broad, and universal rights to all human beings regardless of their gender. It is no doubt that all human beings have equal access to education. This piece of writing not only allows the readers to have the flashback and gain information on what Muslim women did receive and were treated in the past, but also their true rights which are stated in the Noble *Qur'an and Hadiths*. Hopefully, this will bring about a better understanding of Muslim women's rights to and responsibility for education.

Introduction

The issue of gender equity is significant. And debates and writings on this issue are diverse in people's perspectives of various backgrounds. The Islamic perspective on this issue is the least understood, most misrepresented, misinterpreted, or even misperceived by non-Muslims and, at times, by some Muslims as well. It is shown that the dominant local cultural practices in different parts of the world and the actions of some Muslims who are not practicing the true Islam tend to reinforce wrong perceptions of the real Islamic perspective.

When writing or speaking about Islamic position on any issue, one ought to be aware of the Islamic values stated in the Islamic holy book and able to clearly differentiate between the basic teachings of the Islamic fundamentals and the diversity pool of cultural practices prevalent among those adherents that may or may not be consistent with those fundamental teachings of Islam.

Briefly explained, Islam is a religion of peace, unity, love, understanding, and tolerance. Its holy book is called *Qur'an (the recorded words of Allah – Allah is the proper name of God in Islam and is not used to denote any being)* and *Sunnah* (the teachings of His messenger (the last Prophet) Muhammad); and its followers are called Muslims.

Owing to the rights of Muslim women in this unique religion, every Muslim person, male or female from a very young age, is required to pursue education, acquire learning and search for knowledge. Moreover, a human being, male or female, is accountable for his or her actions and deeds on the Day of Resurrection in the hereafter, he or she is required to have the knowledge of the teachings of the *Qur'an* and *Sunnah* particularly, the five basic knowledge of Islamic fundamentals such as *Believing in one God-Allah and His messenger-Muhammad, Prayer, Charity, Fasting,* and *pilgrimage,* etc. Besides that, they are also obliged to know the Attributes of Allah, knowledge of what is lawful and unlawful, right and wrong, their religious obligations, and laws revealed in the *Qur'an* regarding marriage, divorce, inheritance, adultery, murder, theft, etc.

More specifically, Islam crucially provides a great deal of rights and status of a woman in her roles as a mother, a wife, a daughter, and a sister. Her rights regarding inheritance, ownership of property, marriage, divorce, maintenance, acquisition of education, earning of livelihood, participation in any socio-political situations are clearly explained in the *Qur'an* and *Hadith* even though there are some other controversial issues like polygamy, equality between the sexes, woman's right to seek any position as a head of the country, so on and so forth, have been discussed, debated, and disagreed by some scholars from different corners of the world.

Because there are a great deal of rights and responsibilities of women comparable to men in Islam written and revealed in the *Qur'an* and other *Hadiths* (the recoded words and deeds of Allah's messenger Muhammad*)*, Muslim women's rights and responsibility in education specifically are going to be revealed as below.

It is true that in all western and even most Muslim societies of the past, the view of a woman's role was mainly as a wife, a mother, and a housekeeper. Even though the biggest role of a non-Muslim girl in education, at that time, was to spend her time in learning some simple things to fulfill the responsibility for her necessary household jobs or even was forced to stay at home, the

right and responsibility for a Muslim girl was to go to religious school to gain more knowledge on her compulsory daily religious practices. In contrast, it is illustrated in the *Qur'an and Hadiths* that education and knowledge are extremely mandatory upon men and women in Islam. Let us look at what Allah Almighty in His Noble Qur'an and His Messenger Muhammad (peace be upon him) said:

> *Those truly fear God, among his servants, who have knowledge: for God is Exalted in Might, Oft-Forgiving. (Al-Qur'an 35: 28)*

> إِنَّمَا يَخْشَى اللَّهَ مِنْ عِبَادِهِ الْعُلَمَاءُ ۗ إِنَّ اللَّهَ عَزِيزٌ غَفُورٌ
>
> *(Surah Fatir: 35:28)*

> *Are those equal, those who know and those who do not know? It is those who are educated with understanding that receive admonition. (Al-Qur'an 39: 9)*

> قُلْ هَلْ يَسْتَوِي الَّذِينَ يَعْلَمُونَ وَالَّذِينَ لَا يَعْلَمُونَ ۗ إِنَّمَا يَتَذَكَّرُ أُولُو الْأَلْبَابِ
>
> *(Surah Az-Zamar: 39:9)*

And according to Abu Musa Al-Ashari, The Prophet Muhammad said:

> *He who has a slave girl and teaches her good manners and improve her education and then manumits and marries her, will get a double reward; and any slave who observes Allah's right and his master's right will receive a double reward. (translation of Sahih Bukhari, Vol. 3, Book, 46, No. 723)*

Regarding the above revelations and sayings by our beloved Prophet (peace be upon him), it can be clearly inferred that education and knowledge are a must for every Muslim man and woman. Furthermore, since the Prophet Muhammad (peace be upon him) appeared and introduced Islam to the world, he gradually eliminated slavery not only among Muslim but also non-Muslim societies. By the third verse above, we can also infer that women, even if they are slaves, deserve their right and responsibility to gain knowledge and education, and it is compulsory for their master to send them out for knowledge and education. Therefore, Islam pays much attention to both men and women's rights to education and knowledge – religious and academic. As seen in recent years, many young women have decided to devote their time to education from primary to higher level of education in all forms of education: formal, informal, or non-formal, before getting married and having children.

As a Muslim woman having been taught about this issue and by reading the revelations of those rights in the *Qur'an* and the authentic *Sunnah*, I believe that the woman has possessed as many rights as the man has in Islam because the *Qur'an* teaches that men and women are equal in the eyes of Allah Almighty, and that women are always respected and protected.

In addition to her compulsory duty to acquire and search for such knowledge and learning which is essential to her everyday life routines, i.e. management of home, education, training, and bringing up and nurturing her children, she is also required to get educated and trained to become a good mother, a good wife, and a good housekeeper, or even a businesswoman, etc. For the most part, only formal schooling can provide and enable her to accomplish those skills. And that is why today, most countries have full-time education for males and females, Muslim or non-Muslim. Some women pursue Islamic studies at the mosques while many other women go on to university to become as well-educated and qualified, in any fields, such as medical sciences, law, teaching, etc., as their brothers. For example, the two wives of the Prophet (peace be upon him), Khadiiah Binte Kuwaylid, the first wife, was a very wealthy businesswoman. She was the richest woman in Mecca in the ancient time who explored her long trip to Syria by employing a group of men to help with her business, before getting married to the Prophet (peace be upon him). The youngest wife, Aishah Binte Abu Bakr, had a great love for learning and possessed an incredible memory. She was able to recite more than 2,000 verses in the *Qur'an* and narrated them all to other people, especially women. Both were known and considered as the great ladies for their inspiring and leading intellectual abilities to other men and women at that time, and their names and deeds have remained motivational and inspirational for younger generations until now.

In accordance with the obligation that every male and female human being has to fulfill and is required to acquire in this great religion for his or her every day actions and deeds, such search for further knowledge and education also helps release his or her sins in the hereafter as well. Therefore, the woman, being the best companion to the man, need to spare her time seeking knowledge and education in order to make herself become a better self and useful member for her family and society, and more importantly, a meaningful citizen contributing to the development of her country's socio-economic status, and thus to the world.

As it is revealed in the *Qur'an* that wisdom and an increase in knowledge is needed for every human being, I would like to quote one verse from the *Qur'an* as follows:

> *Wisdom and knowledge is a great treasure and everlasting wealth. He is Allah who gives wisdom to whom He likes. Unto whom wisdom is given, he has indeed been blessed with a great treasure.*
>
> *(Al-Qur'an 2: 269)*

يُؤْتِي الْحِكْمَةَ مَنْ يَشَاءُ ۚ وَمَنْ يُؤْتَ الْحِكْمَةَ فَقَدْ أُوتِيَ خَيْرًا
كَثِيرًا ۗ وَمَا يَذَّكَّرُ إِلَّا أُولُو الْأَلْبَابِ

*(Surah Al-Baqara: 2:269)*

According to this verse, it is inferred that every human being is the best of Allah's creation and it is because God has given him or her knowledge, it is one's responsibility and superiority to instill in himself or herself such knowledge and learning. Thus, it is portrayed that every man and woman has the same rights to and responsibility for gaining education and knowledge to accomplish his or her own duty as a true Muslim for one's good life in this temporary world and the hereafter.

So, education or knowledge to both men and women is vital. Without either one, it is hard for the servants (all human beings) of Allah Almighty to understand His scientific miracles and signs since some of them are shown through our normal science and logic.

# សិទ្ធិរបស់ស្ត្រី ក្នុងសាសនាអ៊ិស្លាម

# ស្ត្រី និង ការអប់រំ

ដោយលោកស្រីសាស្ត្រាចារ្យ **ស្នាន ណូរ៉ានី**

កែសម្រួល២០២៣

(១៤៤៥-ម.ស)

ខ្ញុំសង្ឃឹមថា  អត្ថបទនេះនឹងនាំមកនូវការយល់ដឹងប្រសើរជាងមុនអំពីសិទ្ធិ  និង ការទទួលខុសត្រូវនៅក្នុងវិសាលភាពធំមួយនៃការអប់រំដែលស្ត្រីមូស្លីមមាន។

បញ្ហានៃសមភាពយេនឌ័រ គឺមានសារៈសំខាន់ណាស់សម្រាប់សង្គមបច្ចុប្បន្ន។ វាត្រូវបានគេមើលឃើញថាមានការពិភាក្សា និងការសរសេរ នៅលើបញ្ហានេះ កំពុងកើនឡើង និងសម្បូរបែប ក្នុងទស្សនៈរបស់មនុស្សដែលមានប្រវត្តិផ្សេងគ្នា។ ទស្សនៈរបស់សាសនាអ៊ីស្លាមចំពោះបញ្ហានេះ គឺការយល់ដឹងនៅមានកម្រិត ការយល់ខុស ការបកស្រាយខុស ឬសូម្បីតែការសង្កេតឃើញក៏ខុស ដោយក្រុមជនដែលមិនមែនមូស្លីម និងដោយប្រជាជនមូស្លីមមួយចំនួនផងដែរ។ វាត្រូវបានបង្ហាញនូវភាពលេចធ្លោឡើងនូវការប្រណិបត្តិវប្បធម៌ក្នុងស្រុកនៃតំបន់ផ្សេងៗគ្នាលើពិភពលោក ហើយសកម្មភាពរបស់ជនមូស្លីមមួយចំនួនដែលមិនបានអនុវត្តកាតព្វកិច្ចសាសនាអ៊ីស្លាមពិតប្រាកដនោះ បាននាំទៅរកការយល់ឃើញខុសលើទស្សនៈរបស់សាសនាអ៊ីស្លាមពិតប្រាកដ។

នៅពេលសរសេរ ឬនិយាយអំពីជំហរអ៊ីស្លាមលើបញ្ហានីមួយៗ គេគួរតែដឹងនូវតម្លៃអ៊ីស្លាម និងអំពីមូលដ្ឋានគ្រឹះនៃអ៊ីស្លាម ដែលមានចែងក្នុងសៀវភៅសាសនាអ៊ីស្លាម ព្រោះវាមានភាពខុសគ្នាយ៉ាងច្បាស់រវាងការបង្រៀនជាមូលដ្ឋានដែលបានបញ្ជាក់នៅក្នុងគម្ពីររបស់សាសនាអ៊ីស្លាម ជាមួយនឹងភាពសម្បូរបែបនៃការប្រណិបត្តិវប្បធម៌ទូទៅក្នុងចំណោមអ្នកកាន់សាសនា ។

ជាកិច្ចចាប់ផ្តើម ខ្ញុំចង់ណែនាំជូនដោយសង្ខេបនូវអ្វីដែលជាសាសនាអ៊ីស្លាមដ៏ពិតប្រាកដ។ សាសនាអ៊ីស្លាម គឺជាសាសនានៃសន្តិភាព សាមគ្គីភាព ការស្រឡាញ់ ការយល់ដឹង និងការអត់ឱន អធ្យាស្រ័យឲ្យគ្នាតាមរយៈគម្ពីរសាសនា ដែលគេហៅថា គួរអាន (បន្ទូលរបស់ព្រះអល់ឡោះ - ព្រះអល់ឡោះ គឺជានាមច្បាស់លាស់មួយរបស់ព្រះក្នុងសាសនាអ៊ីស្លាម និងមិនត្រូវបានប្រើដើម្បីបញ្ជាក់ជាតុណាមួយឡើយ) និង ស៊ុណ្ណះ(សម្តី ឆន្ទៈ ទង្វើ និងការទទួលស្គាល់របស់ព្យាការីមូហាំម៉ាត់) ដោយអ្នកគោរពតាមទាំងឡាយត្រូវបានគេហៅថាមូស្លីម ។

ដោយឡែកភាពជាម្ចាស់ការលើសិទ្ធិរបស់ខ្លួននៃស្ត្រីមូស្លីមក្នុងសាសនាដែលខុសប្លែកពីគេនេះ មូស្លីមប្រុសស្រីគ្រប់រូប ចាប់តាំងពីវ័យកុមារភាពមក គឺមានកាតព្វកិច្ចដើម្បីស្វែងរកការអប់រំ តម្រូវឲ្យរៀនសូត្រនិងស្វែងរកចំណេះដឹង។ លើសពីនេះទៅទៀតទាំង

បុរសនិងស្ត្រី គឺមានការទទួលខុសត្រូវ លើរាល់សកម្មភាពនិងការប្រព្រឹត្តរបស់ខ្លួនសម្រាប់ថ្ងៃបរលោក ដែលពួកគេត្រូវបានទាមទារឱ្យមាន ចំណេះដឹងអំពីការការបង្រៀននៃគម្ពីរគួរអាន និង ស៊ុណ្ណះ ពិសេសចំណេះដឹងជាមូលដ្ឋានចំនួនប្រាំជាគ្រឹះនៃសាសនាអ៊ីស្លាមដូចជាៈ

ជំនឿ និងធ្វើជាសាក្សីថាគ្មានព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ត្រឹមត្រូវក្រៅពីអល់ឡោះឡើយ ហើយមូហាំម៉ាត់ជាព្យាការីរបស់ទ្រង់ ការថ្វាយបង្គំព្រះ (មួយថ្ងៃមួយយប់ចំនួន៥ដង) សប្បុរសធម៌ដាក់ទាន ការបួសតមអាហារ និងការធ្វើធម្មយាត្រាហាជ្ជី ។ល។

ក្រៅពីនោះពួកគេ ត្រូវបានដាក់កាតព្វកិច្ចផងដែរក្នុងការដឹងគុណចំពោះព្រះអល់ឡោះ ត្រូវមានចំណេះដឹង អំពីអ្វីដែលច្បាប់អនុញ្ញាតិ និងអ្វីដែលខុសច្បាប់ អ្វីដែលត្រូវ និងអ្វីដែលខុស កាតព្វកិច្ចក្នុងសាសនារបស់ពួកគេ និងច្បាប់ដែលបានបង្ហាញនៅក្នុងគម្ពីរគួរអាន ទាក់ទងនឹងការរៀបការ ការលែងលះគ្នា មរតក អំពើផិតក្បត់ ឃាតកម្ម ចោរកម្ម ។ល។

សាសនាអ៊ីស្លាមផ្តល់សិទ្ធិ និងតួនាទីយ៉ាងសំខាន់របស់ស្ត្រី ក្នុងតួនាទីនាងជាម្តាយ ជាប្រពន្ធ ជាកូនស្រី និងបងប្អូនស្រីម្នាក់។ សិទ្ធិរបស់នាងទាក់ទងនឹងមរតក ភាពជាម្ចាស់នៃទ្រព្យសម្បត្តិ អាពាហ៍ពិពាហ៍ ការលែងលះ ការថៃទាំ ការទទួលបានការអប់រំ ប្រាក់សម្រាប់ជីវភាពរស់នៅ ការចូលរួមក្នុងជីវភាពនយោបាយ និងសង្គម ត្រូវបានពន្យល់យ៉ាងច្បាស់នៅក្នុងគម្ពីរគួរអាន និងស៊ុណ្ណះរបស់មូហាំម៉ាត់ ទោះបីជាមានបញ្ហាចម្រូងចម្រាស់មួយចំនួនផ្សេងទៀតដូចជាពហុព័ន្ធភាព សមភាពរវាងភេទ សិទ្ធិរបស់ស្ត្រីក្នុងការស្វែងរកតំណែងជាថ្នាក់ដឹកនាំប្រទេសមួយជាដើម ត្រូវបានគេពិភាក្សា វែកញែកនិងការប្រឆាំងដោយអ្នកខ្លះក៏ដោយ ក៏សិទ្ធិស្ត្រី ត្រូវបានផ្តល់ជូន និងធានាដោយសាសនាអ៊ីស្លាម ។

ដោយយល់ឃើញថាមានសិទ្ធិ និងការទទួលខុសត្រូវជាច្រើនរបស់ស្ត្រីបើប្រៀបធៀបទៅនឹងបុរសក្នុងសាសនាអ៊ីស្លាម ដែលត្រូវបានសរសេរ និងបង្ហាញនៅក្នុងគម្ពីរគួរអាន និង ការកត់ត្រាប្រសាសន៍របស់ព្យាការីមូហាំម៉ាត់(ស៊ុណ្ណះ) ផ្សេងៗ ខ្ញុំនឹងបង្ហាញពីទស្សនៈ និងចំណេះដឹងរបស់ខ្ញុំអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ស្ត្រីមូស្លីមនៅក្នុងវិស័យអប់រំជាពិសេស ហើយអត្ថបទនេះអាចត្រូវបានចាត់ទុកថាជាការសរសេរលើកដំបូងបំផុតរបស់ខ្ញុំអំពីសិទ្ធិរបស់ស្ត្រីមូស្លីម។ វាគឺជាការពិតណាស់ដែលថានៅក្នុងសង្គមនៃលោកខាងលិច និង

សូម្បីតែសង្គមមុនអ៊ីស្លាមបានមកដល់ស្ទើរតែទាំងអស់កាលពីអតីតកាល ទិដ្ឋភាពនៃតួនាទីរបស់ស្ត្រីជាចម្បងគឺ ជាប្រពន្ធ ជាម្ដាយ និង ជាមេផ្ទះម្នាក់។ នៅពេលដែលអ៊ីស្លាមបានមកដល់ដំបូង តួនាទីដ៏ធំបំផុតនៃក្មេងស្រីដែលមិនមែនជាមូស្លីម នៅក្នុងវិស័យអប់រំ នៅពេលនោះ គឺជាការចំណាយពេលវេលារបស់ពួកគេនៅក្នុងការសិក្សាអំពីកិច្ចការងាយៗដ៏សាមញ្ញមួយចំនួនដើម្បីបំពេញនូវការទទួលខុសត្រូវសម្រាប់ការងារចាំបាច់នានាក្នុងគ្រួសាររបស់ពួកគេ ឬក៏ត្រូវបានបង្ខំឱ្យស្នាក់នៅក្នុងផ្ទះ។ ផ្ទុយទៅវិញសិទ្ធិ និងការទទួលខុសត្រូវចំពោះក្មេងស្រីមូស្លីមគឺទៅសាលារៀនសាសនាដើម្បីទទួលបាននូវចំណេះដឹងបន្ថែមទៀតសម្រាប់ការប្រណិបត្តិសាសនាដែលជាកាតព្វកិច្ចប្រចាំថ្ងៃរបស់ពួកគេ។ ជាងនេះទៅទៀតវាត្រូវបានបង្ហាញនៅក្នុងគម្ពីរគួរអាន និងការកត់ត្រាប្រសាសន៍(ស៊ុណ្ណះ) របស់ព្យាការីមូហាំម៉ាត់ ថាការអប់រំ និងចំណេះដឹង គឺជាកាតព្វកិច្ចចាំបាច់បំផុតមកលើបុរសនិងស្ត្រីក្នុងសាសនាអ៊ីស្លាម។ សូមក្រឡេកមើលអ្វីដែល ព្រះអល់ឡោះដ៏មហាឧត្តុង្គឧត្តមបានមានបន្ទូលនៅក្នុងគម្ពីរគួរអាន និងប្រសាសន៍របស់ព្យាការីរបស់ទ្រង់(មូហាំម៉ាត់ សូមសុខសន្តិភាពមានសម្រាប់លោក) ដូចខាងក្រោម:

*ពិតប្រាកដណាស់ អ្នកដែលកោតខ្លាចអល់ឡោះក្នុងចំណោមខ្ញុំរបស់ទ្រង់នោះគឺបណ្ដាអ្នកដែលមានចំណេះដឹង។*
*(អាល់គួរអាន ៣៥:២៨)*

إِنَّمَا يَخْشَى اللَّهَ مِنْ عِبَادِهِ الْعُلَمَاءُ ۗ إِنَّ اللَّهَ عَزِيزٌ غَفُورٌ

*(Surah Fatir: 35:28)*

*តើបណ្ដាអ្នកចេះដឹង និងអ្នកមិនចេះដឹង ស្មើគ្នាដែរឬទេ? ពិតប្រាកដណាស់ មានតែបញ្ញាជនប៉ុណ្ណោះដែលចេះពិចារណា។*
*(អាល់គួរអាន ៣៩:៩)*

قُلْ هَلْ يَسْتَوِي الَّذِينَ يَعْلَمُونَ وَالَّذِينَ لَا يَعْلَمُونَ ۗ إِنَّمَا يَتَذَكَّرُ أُولُو الْأَلْبَابِ

*(Surah Az-Zamar: 39:9)*

យោងតាម អាប៊ូមូសា អាល់អាស់អារីបានរាយការណ៍ថា ព្យាការីមូហាំម៉ាត់(សូមសុខសន្តិភាពមានសម្រាប់លោក)បានមានប្រសាសន៍ថា:

> *អ្នកណាហើយដែលមានទាសករជានារីភេទ ចូរបង្រៀននូវអាកប្បកិរិយាល្អឲ្យពួកនាង និងបង្កើននូវការអប់រំដល់ពួកនាង ហើយបន្ទាប់មកត្រូវដោះលែងឲ្យនាងមានសិទ្ធិសេរីភាព និងរៀបការឲ្យនាង អ្នកនោះនឹងទទួលបានរង្វាន់(ផលបុណ្យ)ពីរដង! ហើយទាសករណាដែលបានដឹងគុណព្រះអល់ឡោះ និងដឹងគុណម្ចាស់របស់ខ្លួនគេ នឹងទទួលបានរង្វាន់(ផលបុណ្យ)ពីរដងដែរ។*
>
> *(បកប្រែ Sahih Bukhari លេខ៣ សៀវភៅ ៤៦ លេខ ៧២៣ )*

ទាក់ទងនឹងបន្ទូលរបស់អល់ឡោះ និងប្រសាសន៏របស់ព្យាការីយើង(សូមសុខសន្តិភាពមានដល់លោក) ខាងលើ យើងអាចសន្និដ្ឋានបានយ៉ាងច្បាស់ថា ការអប់រំ និងចំណេះដឹង គឺជាកាតព្វកិច្ចសម្រាប់រាល់មូស្លីមទាំងបុរស និងស្ត្រី ។ លើសពីនេះទៀតចាប់តាំងពីមានវត្តមានព្យាការីមូហាំម៉ាត់ ( សូមសុខសន្តិភាពមានដល់លោក ) បន្ទាប់ពីបានណែនាំសាសនាអ៊ីស្លាមទៅកាន់ពិភពលោកនោះ លោកបានលុបបំបាត់ជាបន្តបន្ទាប់នូវទាសភាព មិនតែសម្រាប់សង្គមមូស្លីមនោះទេ ប៉ុន្តែក៏មានក្នុងសង្គមមិនមែនជាអ្នកកាន់សាសនាអ៊ីស្លាមផងដែរ។ តាមរយៈកឋាខ័ណ្ឌទីបី ខាងលើយើងក៏អាចយល់បានដែរថា ស្ត្រីទោះបីជាពួកគេជាទាសករ ក៏ពួកគេ ទទួលបាននូវ សិទ្ធិ និងការទទួលខុសត្រូវ ដើម្បីទទួលបាននូវ ចំណេះដឹង និងការអប់រំ ហើយវាជាកាតព្វកិច្ចចាំបាច់បំផុតរបស់ម្ចាស់ពួកគេក្នុងការបញ្ជូនពួកគេចេញទៅស្វែងរកចំណេះដឹង និងការអប់រំ។ ដូច្នេះសាសនាអ៊ីស្លាមយកចិត្តទុកដាក់ជាខ្លាំងចំពោះសិទ្ធិក្នុងការទទួលបានការអប់រំ និងចំណេះដឹង សម្រាប់មូស្លីមបុរស និងនារី ទាំងចំណេះដឹងផ្នែកសាសនា និងចំណេះដឹងផ្នែកវិទ្យាសាស្ត្រ។

ជាលទ្ធផល ដូចដែលគេបានឃើញនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ស្ត្រីវ័យក្មេងជាច្រើនបានសម្រេចចិត្ត ចំណាយពេលវេលារបស់ពួកគេដើម្បីការអប់រំ ចាប់ពីបឋមសិក្សា រហូតដល់ឧត្តមសិក្សានៅក្នុងគ្រប់ទម្រង់ទាំងអស់នៃប្រព័ន្ធអប់រំដែលបានរៀបចំដោយរដ្ឋ តាំងពីមុនពេលរៀបការ ឬនិងបន្ទាប់ពីការរៀបការរួច ។

ក្នុងនាមជាស្ត្រីមូស្លីមមួយរូប ដែលត្រូវបានបង្រៀនអំពីបញ្ហាទាំងនេះ និងដោយការអានយល់ជ្រួតជ្រាបនូវសិទ្ធិទាំងអស់នោះនៅក្នុង គម្ពីរគួរអាន និង ស៊ុណ្ណះ ដ៏ត្រឹមត្រូវនេះ ខ្ញុំជឿជាក់ថា ស្ត្រីមានសិទ្ធិជាច្រើន ដូចបុរសនៅក្នុងសាសនាអ៊ីស្លាម ព្រោះគម្ពីរគួរអានបានបង្រៀនថា បុរស និងស្ត្រី គឺស្មើគ្នានៅចំពោះ ព្រះអល់ឡោះដ៏មហិមា ហើយថាស្ត្រី ត្រូវបានគោរព និងការពារជានិច្ច។

ក្រៅពីកាតព្វកិច្ចចាំបាច់របស់នាងក្នុងការទទួលបាន និងស្វែងរកចំណេះដឹង និងការរៀនសូត្រនូវអ្វីដែលជាមូលដ្ឋានសម្រាប់សកម្មភាពប្រចាំថ្ងៃក្នុងជីវិតរបស់នាង ពោលគឺការគ្រប់គ្រងផ្ទះ ការអប់រំ បណ្តុះបណ្តាល និងការថែទាំចិញ្ចឹមបីបាច់កូនរបស់នាង ពួកនាងត្រូវបានទាមទារផងដែរដើម្បីទទួលបាននូវការអប់រំ និងការបណ្តុះបណ្តាលឲ្យក្លាយទៅជាម្តាយដ៏ល្អ ប្រពន្ធល្អ និងជាមេផ្ទះដ៏ល្អមួយរូប ជាអាជីវករ ឬអ្នកអប់រំមួយរូប ដ៏ល្អ ។ល។ ហើយមានតែការសិក្សាជាផ្លូវការទេ ដែលអាចផ្តល់ជូន និងនាំមកនូវការសម្រេចបាននូវជំនាញ ទាំងនោះជូននាង។ នោះហើយជាមូលហេតុដែលនាពេលបច្ចុប្បន្ននេះប្រទេសភាគច្រើន មានការអប់រំពេញម៉ោងសម្រាប់ បុរស និងស្ត្រីមូស្លីម ឬមិនមែនមូស្លីម។ ស្ត្រីមួយចំនួនចូលរៀនសាសនាអ៊ីស្លាម នៅតាមវិហារអ៊ីស្លាម ខណៈពេលដែលស្ត្រីជាច្រើនផ្សេងទៀតចូលរៀននៅតាមសាកលវិទ្យាល័យនានា ដើម្បីទទួលបានការអប់រំដ៏ល្អ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យជាច្រើន ដូចជា វេជ្ជសាស្ត្រ មេធាវី គ្រូបង្រៀន។ល។ ដូចបងប្អូនប្រុស របស់ពួកគេ។ ជាឧទាហរណ៏ ប្រពន្ធពីររូបនៃព្យាការីមូហាំម៉ាត់ (សូមសេចក្តីសុខសន្តិភាពមានចំពោះលោក) ដែលប្រពន្ធទីមួយឈ្មោះ ខទីចះ ពិនទី យូវៃលីត (Khadiiah Binte Kuwaylid) គឺជា អ្នកជំនួញមានទ្រព្យសម្បត្តិយ៉ាងច្រើន។ ជាស្ត្រីដែលមានជាងគេបំផុតនៅក្នុងទីក្រុង Mecca នាសម័យបុរាណ ដែលបានធ្វើដំណើរដ៏វែងឆ្ងាយ

របស់គាត់ទៅកាន់ប្រទេសស៊ីរី ដោយបានជួលក្រុមបុរសជាច្រើន ដើម្បីជួយនៅក្នុងអាជីវកម្មរបស់គាត់។ ហើយមុនពេលរៀបការជាមួយព្យាការីមូហាំម៉ាត់

(សូមសេចក្តី សុខសន្តិភាពមានចំពោះលោក) ប្រពន្ធក្មេងបំផុត ឈ្មោះ អៃសាស់ ពិនទី អាពូពើកើត (Aishah Binte Abu Bakr) មានការជក់ចិត្ត ស្រឡាញ់ការរៀនសូត្រ និងមានកម្រិតចងចាំល្អមួយដែលមិនគួរឱ្យជឿ។ គាត់អាចសូត្របានច្រើនជាង ២០០០ឃ្លា នៅក្នុងគម្ពីរគួរអាន និងបានសូត្រឱ្យមនុស្សម្នាផ្សេងទៀតបានស្តាប់ ជាពិសេសពួកស្ត្រីៗ។ អ្នកទាំងពីរត្រូវបានគេស្គាល់និង ចាត់ទុកថាជាស្ត្រីដ៏អស្ចារ្យសម្រាប់ការជម្រុញលើកទឹកចិត្ត និងឈានមុខគេនូវសមត្ថភាពនិងបញ្ញារបស់ពួកគេទៅលើបុរសនិងស្ត្រីផ្សេងទៀតនៅពេលនោះ ហើយឈ្មោះ និងការប្រព្រឹត្តរបស់ពួកគេនៅតែជំរុញទឹកចិត្តនិងការបំផុសគំនិតសម្រាប់មនុស្សជំនាន់ក្រោយ រហូតមក ដល់បច្ចុប្បន្ននេះ។

ដោយអនុលោមទៅនឹងកាតព្វកិច្ចដែលថា រាល់បុរស និងស្ត្រីត្រូវបំពេញ និងត្រូវបានទាមទារសម្រេច ឲ្យបាននៅក្នុងសាសនាដ៏អស្ចារ្យមួយនេះ ពួកគេក៏ត្រូវធ្វើកិច្ចប្រណិបត្តិជារៀងរាល់ថ្ងៃនូវការស្វែងរកចំនេះដឹង និងការអប់រំបន្ថែមទៀត ដើម្បីអាចជួយបន្ថយបាបកម្មរបស់ពួកគេនៅក្នុងថ្ងៃបរលោកផងដែរ។ ដូច្នេះក្នុងនាមជាដៃគូដ៏ល្អរបស់បុរស ស្ត្រីចាំបាច់ត្រូវទុកពេលវេលារបស់នាងក្នុងការស្វែងរកចំណេះដឹង និងការអប់រំ គោលបំណងដើម្បីធ្វើឱ្យខ្លួនឯងក្លាយជាសមាជិកដែលមានប្រយោជន៍ដល់គ្រួសារ និងសង្គម ហើយសំខាន់ជាងនេះទៀតគឺដើម្បីក្លាយជាពលរដ្ឋល្អចូលរួមចំណែកដល់ការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ប្រទេសជាតិ ក៏ដូចជាពិភពលោកទាំងមូលផងដែរ។ ប្រាជ្ញា និងចំណេះដឹង គឺជាទ្រព្យសម្បត្តិដ៏អស្ចារ្យ និងជាទ្រព្យសម្បត្តិអស់កល្បជានិច្ច។

ដូចមានចែងនៅក្នុងគម្ពីរគួរអានថា ប្រាជ្ញា និងការបង្កើនចំណេះដឹង ត្រូវការជាចាំបាច់សម្រាប់មនុស្សគ្រប់រូប។ខ្ញុំសូមដកស្រង់ឃ្លាមួយពីក្នុងគួរអាន ដូចខាងក្រោម:

*គឺព្រះអល់ឡោះ ដែលប្រទានប្រាជ្ញា ភាពឈ្លាសវៃដល់អ្នកណាដែលទ្រង់ប្រាថ្នា ។ ហើយអ្នកណាដែលត្រូវបានទ្រង់ប្រទាននូវភាពឈ្លាសវៃ អ្នកនោះប្រាកដជាត្រូវប្រទានឲ្យនូវភាពល្អប្រសើរដ៏ច្រើនលើសលប់។ ( អាល់គួរអាន ២: ២៦៩ ) ។*

يُؤْتِي الْحِكْمَةَ مَنْ يَشَاءُ ۚ وَمَنْ يُؤْتَ الْحِكْمَةَ فَقَدْ أُوتِيَ خَيْرًا كَثِيرًا ۗ وَمَا يَذَّكَّرُ إِلَّا أُولُو الْأَلْبَابِ

*(Surah Al-Baqara: 2:269)*

យោងតាមឃ្លាខាងលើក្នុងគម្ពីរគួរអាន យើងអាចសន្និដ្ឋានបានថា មនុស្សគ្រប់រូបគឺជាសភាវៈដ៏ប្រសើរថ្លៃថ្លាបំផុតដែលអល់ឡោះបានបង្កើត គឺដោយសារតែអល់ឡោះបានប្រទាននូវប្រាជ្ញា និងចំនេះដឹងដល់ពួកគេ ហើយវាគឺជាសច្ចភាព និងឧត្តមភាពក្នុងការស្វែងរកចំនេះដឹងនិង ការរៀនសូត្រគ្រប់បែបយ៉ាង។

ដូច្នេះយើងអាចគូសបញ្ជាក់ថា បុរស និងស្ត្រីមានសិទ្ធិដូចគ្នានិងការទទួលខុសត្រូវក្នុងការទទួលបាននូវការអប់រំ និងចំណេះដឹង ដើម្បីសម្រេចកាតព្វកិច្ចរបស់ខ្លួនជាមូស្លីមដ៏ពិតប្រាកដ សម្រាប់ជីវិតដ៏ថ្លៃថ្លា នៅក្នុងលោកីយនេះ និងបរលោក។

ដូច្នេះហើយការអប់រំ និងចំណេះដឹងសម្រាប់បុរស និងស្ត្រីគឺមានសារៈសំខាន់ខ្លាំងណាស់។ បើគ្មានផ្នែកណាមួយ វាជាការលំបាកណាស់សម្រាប់ពួកបំរើទាំងឡាយ( មនុស្សទាំងអស់ )របស់ព្រះអល់ឡោះ ដើម្បីយល់ពីសញ្ញា និងភាពអស្ចារ្យនៃវិទ្យាសាស្ត្ររបស់ទ្រង់ដែលផ្នែកមួយចំនួនត្រូវបានបង្ហាញ តាមរយៈចំណេះផ្នែកវិទ្យាសាស្ត្រ និងតក្កវិជ្ជាសាមញ្ញរបស់យើង។

អត្ថបទនេះមិនត្រឹមតែ ជួយឱ្យអ្នកអាន អាចឆ្លុះបញ្ចាំងពីអតីតកាល និងការទទួលបានព័ត៌មានបន្ថែមនៅលើអ្វីដែល ស្ត្រី មិនមែនជាមូស្លីមនិងស្ត្រីមូស្លីមបានទទួល និងត្រូវបានគាំពារក្នុងពេលកន្លងមក ប៉ុន្តែក៏បានបង្ហាញពីសិទ្ធិពិតប្រាកដរបស់ពួកគេ ដែលត្រូវបានចែងក្នុងគម្ពីរគួរអានដ៏មហាឧត្តុងឧត្តម និងការកត់ត្រាប្រសាសន៍ (ស៊ុណ្ណះ) របស់ព្យាការីមូហាំម៉ាត់។

References

Al-Qur′an Khmer translation. Surah 35, Verse 28, Surah 39, Verse 9, Surah 2, Verse 269. Retrieved from https://quranenc.com/en/browse/khmer_cambodia.

Hedayati, A. (2023). Women′s education from the perspectives of Islam and consequences of restrictions on women of education in Afghanistan. *Sprin Journal of arts, Humanities and Social Sciences, 2*(8), pp. 1-9. doi: 10.55559/sjahss.v2i08.125

Karim, A. Z. (1394). Women′s rights and duties in Islam, translator: Soheila, Rostami, bija, bina.

Immamudin, M. et al., (2020). The roles of women as educators. *Nur El-Islam, 7*(2), pp. 139-157.

Raga′ El-Nimr, (1996). *Women in Islamic law in Mai Yamani, ed. Feminism and Islam legal and literary perspective,* New York. New York University Press.

Sahih Bukhari Volume 3 Book 46 Number 723.